# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២០៩.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលលើកំណត់សម្គាល់ II នៃឧបសម្ព័ន្ធ២
## នៃអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧
## ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ -
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ រៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលខ្លឹមសារនៅក្នុងកំណត់សម្គាល់ II នៃឧបសម្ព័ន្ធ២ របស់អនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ ពី " បញ្ជីនេះមិនអនុវត្តចំពោះការនាំចេញឬនាំចូលដែលគ្មានលក្ខណៈពាណិជ្ជកម្មតាមរូបភាពជាទំនិញគំរូ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកធ្វើដំណើរ សម្ភារៈផ្លាស់ប្តូរលំនៅឋានឬតាមរូបភាពប្រហាក់ប្រហែល។ ការលើកលែងនេះ មិនអនុវត្តចំពោះមុខទំនិញដែលស្ថិតក្រោមមុខសញ្ញាហាមឃាត់ដាច់ខាតក្នុងការនាំចេញ នាំចូល ឬប្រភេទមានហានិភ័យខ្ពស់ដល់សុវត្ថិភាពសាធារណៈ " ទៅជា " បញ្ជីនេះមិនអនុវត្តចំពោះការនាំចេញឬនាំចូល ដែលគ្មានលក្ខណៈពាណិជ្ជកម្មតាមរូបភាពជាទំនិញគំរូ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកធ្វើដំណើរ សម្ភារៈផ្លាស់ប្តូរលំនៅឋានឬករណីតាមរូបភាពប្រហាក់ប្រហែល ព្រមទាំងការនាំចេញមានលក្ខណៈពាណិជ្ជកម្ម នូវផលិតផលដែលផលិតពីឈើ (ឈើដាំក្នុងស្រុក) ឬស្សី ផ្តៅ ដើមត្នោត កក់ ឬពាក់ ជាស្នាដៃសិប្បករសម្រាប់ប្រើក្នុងលំនៅឋាន វត្ថុតុបតែងលម្អ និងរូបចម្លាក់ផ្សេងៗ ដែលមានកម្រិតខ្នាតតិចជាង៥គីឡូក្រាមក្នុងមួយឯកតា។ ការលើកលែងនេះ មិនអនុវត្តចំពោះទំនិញដែលស្ថិតក្រោមមុខសញ្ញាហាមឃាត់ដាច់ខាតក្នុងការនាំចេញឬនាំចូលឬប្រភេទមានហានិភ័យខ្ពស់ដល់សុវត្ថិភាពសាធារណៈ " វិញ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ



www.pheakdeylaw.com

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍផ្នែកឯកជ
ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៣*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*



បណ្ណាគារ ភក្តីឡច
PheakdeyLaw Book Store
www.pheakdeylaw.com